**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

******

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៦.០៨៣/០៨ គ.ជ.ប.អគ្គ.ពស**

ភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៨

# គ.ជ.ប បន្ថែមឈ្មោះអ្នកបោះឆ្នោតចំនួន ១.១៣៨ នាក់ ទៅក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០០៧ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ឆ្នាំ២០០៨

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានសម្រេចបន្ថែមឈ្មោះអ្នកបោះឆ្នោតចំនួន ១.១៣៨ នាក់ទៀត ទៅក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០០៧ ដែលធ្វើឱ្យអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតសរុបចំនួន **៨.១២៥.៥២៩** នាក់។

ករណីនេះត្រូវបាន គ.ជ.ប ប្រជុំសម្រេចកាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨។ ឈ្មោះអ្នកបោះឆ្នោតដែលត្រូវបាន បញ្ចូលក្នុងបញ្ជីបោះឆ្នោតនោះមាននៅក្នុងសង្កាត់ស្ទឹងមានជ័យ ក្រុងភ្នំពេញ។

គ.ជ.ប បានសម្រេចឱ្យនាយកដ្ឋានប្រតិបត្តិការៈ

- បញ្ចូលឈ្មោះអ្នកបោះឆ្នោតខាងលើទៅក្នុងការិយាល័យបោះឆ្នោតនៃសង្កាត់ស្ទឹងមានជ័យ
- បោះពុម្ពបញ្ជីបោះឆ្នោតនៃសង្កាត់ស្ទឹងមានជ័យសាជាថ្មី
- ធ្វើប័ណ្ណព័តិមានអ្នកបោះឆ្នោត សម្រាប់សង្កាត់ស្ទឹងមានជ័យសាជាថ្មីឱ្យទាន់មុនថ្ងៃចែក (ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៨)
- ថតចម្លងបញ្ជីបោះឆ្នោតសង្កាត់ស្ទឹងមានជ័យជាស៊ីឌី សម្រាប់ចែកជូនអ្នកដែលបានជាវបញ្ជីបោះឆ្នោតជាស៊ីឌីពី គ.ជ.ប ដោយឥតគិតថ្លៃ
- បន្ថែមសន្លឹកឆ្នោត សម្រាប់ការិយាល័យបោះឆ្នោតដែលបានបញ្ចូលអ្នកបោះឆ្នោត ដោយប្រើសន្លឹកឆ្នោតបម្រុង សម្រាប់ក្រុងភ្នំពេញ។

ជាមួយគ្នានេះដែរ គ.ជ.ប ក៏បានសម្រេចបំបែកការិយាល័យលេខ ១០៧៥ ក្នុងសង្កាត់ស្ទឹងមានជ័យ ក្រុងភ្នំពេញ ជាការិយាល័យភ្លោះ។ ដូច្នេះការិយាល័យបោះឆ្នោតសរុបទូទាំងប្រទេសមានចំនួន **១៥.២៥៥** ការិយាល័យ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា នេះជាការធ្វេសប្រហែសរបស់ស្មៀន និងក្រុមប្រឹក្សាសង្កាត់ស្ទឹងមានជ័យ ក្នុងការបញ្ជូនបញ្ជីបោះឆ្នោតមក គ.ជ.ប ពីព្រោះឈ្មោះអ្នកបោះឆ្នោតទាំងនោះ ត្រូវបានឆូតលុបចេញពីទម្រង់១០២៥ គឺមានន័យថា ឈ្មោះអ្នកទាំងនោះត្រូវបានរក្សាទុកក្នុងបញ្ជីបោះឆ្នោតនៃសង្កាត់ស្ទឹងមានជ័យដដែល ប៉ុន្តែស្មៀន និងក្រុមប្រឹក្សាសង្កាត់បានបញ្ជូនឈ្មោះអ្នកទាំងនោះ ដែលមាននៅក្នុងទម្រង់១០២៥មក គ.ជ.ប។

ព័តិមានបន្ថែមសូមទំនាក់ទំនងទូរស័ព្ទលេខ: ០២៣ ២១៤ ៣៧៤ / ០១២ ៨៥៥ ០១៨ E-mail: necinfo@forum.org.kh, Web-site: www.necelect.org.kh